# កិច្ចព្រមព្រៀង

## រវាង

## ក្រុមហ៊ុន អូរៀរ ហូថេល (ខេមបូឌា) ឯ.ក

## និង

## តំណាងកម្មករ និយោជិត

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ០៩ និង ០០នាទី នៅក្នុងក្រុមហ៊ុន អូរៀរ ហូថេល (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករ និយោជិត។

នៅក្នុងអង្គប្រជុំនេះតំណាងនាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្នពីបញ្ហាជំងឺកូវីត១៩ដែលបានផ្ទុះឡើងនិងកំពុងតែរាតត្បាតយ៉ាងខ្លាំងទូទាំងពិភពលោកនាពេលនេះបានបង្ខំអោយរដ្ឋាភិបាលត្រូវចាត់វិធានការណ៍ចាំបាច់មួយចំនួនដើម្បីការពារនូវការឆ្លងរាលដាលនៃជំងឺដ៏កាចសាហាវនេះក្នុងស្ថានភាពនេះដែរក៏បានធ្វើអោយមានផលប៉ះពាល់ដល់អាជីវកម្មមួយចំនួនរាប់បញ្ចូលទាំងវិស័យទេសចរណ៍ រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋានជាដើម។ ហើយក្នុងនោះក៏រាប់បញ្ចូលទាំងសណ្ឋាគារ អូរៀរ ផងដែរ ។ ហេតុដូចនេះ ខាងសណ្ឋាគារបានសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិត ចំនួន៣០នាក់ (ស្រី២០នាក់) រយះពេលចំនួនពីរ (២) ខែដោយគិតពី ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០។ នៅក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះកម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួលហាសិបភាគរយ(៥០%) ក្នុងមួយខែ នៃប្រាក់ខែគោលប្រចាំខែរបស់កម្មករ និយោជិតម្នាក់ៗ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ១០ និង ០០នាទី នាថ្ងៃខែនិងឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវនិងសហការគ្នាយ៉ាង រលូន។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០

តំណាងកម្មករ និយោជិត

លោកស្រី ម៉ម ច័ន្ទពុទ្ធារី

លោកស្រី ទ្រឿង ចាន់ណា

កញ្ញា តាំង ឌីយ៉ាកន្និកា

ហត្ថលេខា និងត្រា

នាយកក្រុមហ៊ុន